# PONLOK CHOMNES

ទិន្នន័យ និងការពិភាក្សា ដើម្បីការអភិវឌ្ឍនៅកម្ពុជា



ដោយផ្អែកលើពិសោធន៍ទទួលបានពីការអនុវត្ត កម្មវិធីពន្លកចំណេះ ដំណាក់កាលទី១ (២០១៩-២០២៣) ដែលមានគោលបំណងពង្រឹងសមត្ថភាពរបស់ស្ថាប័នស្រាវជ្រាវនៅកម្ពុជា ដើម្បីជានាគុណភាពនៃការស្រាវជ្រាវ អង្គការមូលនិធិអាស៊ី នឹងអនុវត្ត **កម្មវិធីពន្លកចំណេះ៖ ទិន្នន័យ និងការពិភាក្សាដើម្បីការអភិវឌ្ឍនៅកម្ពុជា ដំណាក់កាលទី២ (២០២៣-២០២៧)។** ដោយមានការគាំទ្រពីក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី កម្មវិធីពន្លកចំណេះ មានគោលបំណងរួមចំណែកដល់ការសម្រេចចិត្តផ្អែកគោលនយោបាយសាធារណៈ ដែលផ្អែកលើទិន្នន័យ និងមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ត្រូវបានអនុវត្ត និងក្លាយជាបទដ្ឋាន។

## លទ្ធផលរំពឹងទុករបស់កម្មវិធីពន្លកចំណេះ

**លទ្ធផលអន្តរកាលទី ១**

ការស្រាវជ្រាវគោលនយោបាយត្រូវបានធ្វើឡើងដោយផ្អែកលើប្រភពទិន្នន័យចម្រុះ និងប្រកបដោយបរិយាបន្ន

**លទ្ធផលអន្តរកាលទី ២**

លទ្ធផលនៃការស្រាវជ្រាវគោលនយោបាយត្រូវបានផ្សព្វផ្សាយដល់ក្រុមគោលដៅចម្រុះយ៉ាងមានប្រសិទ្ធភាព

**លទ្ធផលអន្តរកាលទី ៣**

ដំណើរការកិច្ចពិភាក្សាគោលនយោបាយប្រកបដោយបរិយាបន្នត្រូវបានអនុវត្ត និងសាកល្បងជាមួយតួអង្គចម្រុះ

**លទ្ធផលអន្តរកាលទី ៤**

ស្ត្រី (និងក្រុមដែលត្រូវបានផាត់ចេញផ្សេងទៀត) ចូលរួមយ៉ាងសកម្មក្នុងដំណើរការស្រាវជ្រាវ និងកិច្ចពិភាក្សាគោលនយោបាយ

**លទ្ធផលរំពឹងទុករបស់កម្មវិធី**

នៅឆ្នាំ២០២៧ ដំណើរការតាក់តែងគោលនយោបាយសាធារណៈលើវិស័យមួយចំនួននឹងមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន ព្រមទាំងរៀបចំឡើងដោយផ្អែកលើទិន្នន័យចម្រុះ និងអាចទុកចិត្តបាន

**ការដាក់បញ្ចូលសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម និងការប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីទាំងមូល**

Australian Aid

The Asia Foundation

“អង្គការមូលនិធិអាស៊ី បានរួមចំណែកលើកកម្ពស់សន្តិភាព និងវិបុលភាពប្រជាជនកម្ពុជា តាំងពីឆ្នាំ១៩៥៥”

## យន្តការរបស់កម្មវិធី

### ការរៀបចំយន្តការ

កំណត់ និងផ្តោតលើឱកាស ជាជាងផ្តោតលើបញ្ហា

### សមាហរណកម្ម

ដាក់បញ្ចូលសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

### ការពិសោធ

សាកល្បងគំរូនៃការស្រាវជ្រាវ និងការពិភាក្សាបែបបរិយាបន្ននៅក្នុងដំណើការគោលនយោបាយ

## ប្រធានបទដែលត្រូវបានជ្រើសរើស*

- ការប្រែប្រួលអាកាសធាតុ របរចិញ្ចឹមជីវិត និងទេសន្តរប្រវេសន៍
- ការប្រើប្រាស់បច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុនៅក្នុងវិស័យកសិកម្ម
- ការអប់រំប្រកបដោយគុណភាព និងបរិយាបន្ន
- ការពិចារណាឡើងវិញអំពីគម្រូនៃការអភិវឌ្ឍជនបទ
- ការរិះរកគំនិតថ្មីៗពាក់ព័ន្ធនឹងអាស៊ាន
- ស្ត្រី សន្តិភាព និងសន្តិសុខ

*ប្រធានបទដែលបានជ្រើសរើសមានភាពបត់បែន។ កម្មវិធីពន្លកចំណេះ អាចដាក់បញ្ចូលប្រធានបទផ្សេងទៀត ឬផ្លាស់ប្តូរទៅតាមវឌ្ឍនភាពជាក់ស្តែង។

### ការគាំទ្រអ្នកស្រាវជ្រាវក្នុងស្រុក

គាំទ្រអ្នកស្រាវជ្រាវវ័យក្មេងតាមរយៈកម្មវិធីផ្សេងៗ

### ការកំណត់គោលជំហរនៅក្នុងដំណើរការគោលនយោបាយ

ផ្តោតលើការកសាងទំនាក់ទំនង ទំនុកចិត្ត ការទទួលយក និងការពង្រីកបណ្តាញទំនាក់ទំនង

## សកម្មភាពរបស់យើង

### ទិន្នន័យចម្រុះ និងអាចទុកចិត្តបាន

ពង្រឹងការស្រាវជ្រាវដែលផ្អែកលើប្រភពទិន្នន័យចម្រុះ និងប្រកបដោយបរិយាបន្ន

### ការពិភាក្សាប្រកបដោយបរិយាបន្ន

ដំណើរការពិភាក្សាគោលនយោបាយដែលមានការចូលរួមសហការប្រកបដោយបរិយាបន្ន

### ការផ្សព្វផ្សាយយ៉ាងមានប្រសិទ្ធភាព

ផ្សព្វផ្សាយលទ្ធផលនៃការស្រាវជ្រាវគោលនយោបាយដល់ក្រុមគោលដៅចម្រុះយ៉ាងមានប្រសិទ្ធភាព

### ការចូលរួមប្រកបដោយអត្ថន័យ

បង្កើនសំឡេងរបស់ស្ត្រី ជនមានពិការភាព និងក្រុមងាយរងគ្រោះផ្សេងទៀតនៅក្នុងសកម្មភាពរបស់កម្មវិធី

## ដៃគូរបស់កម្មវិធី

### ផ្តោតទៅលើភាពជាដៃគូ

ផ្តោតលើចំណាប់អារម្មណ៍ និងភាពខ្លាំងរបស់ដៃគូ

### ការគាំទ្រភាពជាដៃគូ

រាជរដ្ឋាភិបាល អ្នកសិក្សាស្រាវជ្រាវ អង្គការសង្គមស៊ីវិល អ្នកស្រាវជ្រាវវ័យក្មេង ដៃគូអភិវឌ្ឍន៍ និងសហគមន៍

### គណៈកម្មាធិការប្រឹក្សាផ្នែកបច្ចេកទេស

ត្រូវបានផ្តួចផ្តើមឡើងដោយមានការចូលរួមពីតំណាងរាជរដ្ឋាភិបាល អ្នកជំនាញ អ្នកស្រាវជ្រាវ និងអង្គការសង្គមស៊ីវិល

#### ដៃគូយុទ្ធសាស្ត្រ

វិទ្យាស្ថានស្រាវជ្រាវកម្ពុជាចំនួន៥ នឹងធ្វើការស្រាវជ្រាវគោលនយោបាយ ផ្សព្វផ្សាយ និងរៀបចំការពិភាក្សា

#### ក្រុមជំនាញផ្នែកសមភាពយេនឌ័រ ពិការភាព និងបរិយាបន្នសង្គម

អង្គការសង្គមស៊ីវិលក្នុងស្រុកចំនួន៣ ដែលមានជំនាញផ្នែកសមភាពយេនឌ័រ និងសិទ្ធិជនមានពិការភាព

#### ដៃគូនវានុវត្តន៍

ថវិកាអនុវត្តសកម្មភាពកញ្ចប់តូចចំនួន ៦ នឹងគាំទ្រដល់ការស្រាវជ្រាវ និងការពិភាក្សាប្រកបដោយនវានុវត្តន៍

ថវិកាអនុវត្តសកម្មភាពដែលមានការចូលរួមសហការពីរាជរដ្ឋាភិបាល

#### បណ្តាញស្ត្រីក្នុងវិស័យស្រាវជ្រាវ (SheThinks Network)

មានគោលបំណងលើកកម្ពស់ការចូលរួមរបស់ស្ត្រី និងពង្រឹងបរិយាបន្នក្នុងវិស័យស្រាវជ្រាវ

## សូមចូលរួមជាមួយយើង

www.policypulse.org

policypulse@asiafoundation.org

@PonlokChomnes

@AustralianEmbassyPhnomPenh

@PonlokChomnes

@PonlokChomnes